**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខៈ ០៦៧/១៥ ក.អ.ជ-ហក

ថ្ងៃអង្គារ ១៣ រោច ខែផល្គុន ឆ្នាំមមែ ព.ស.២៥៥៨
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ០៣ គ.ស ២០១៥

# ប្រកាស
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការបន្ថែមសម្រាប់បំពេញការងារនៅក្នុងអង្គភាពគ្រប់គ្រងគម្រោងកែលម្អផ្លូវជនបទដំណាក់កាលទី ២ ក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងហិរញ្ញប្បទានពីមូលនិធិសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ចកូរ៉េ (EDCF)

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវនីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍
- យោងអនុស្សរណៈយោគយល់គ្នារវាងក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ ២០១៥
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ១.-** តែងតាំងមន្ត្រីរាជការសម្រាប់បំពេញការងារក្នុងគម្រោងកែលម្អផ្លូវជនបទដំណាក់កាលទី ២ ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. | លោក | ដន ដារ៉ា | ជាមន្ត្រីដោះស្រាយផលប៉ះពាល់ |
| ២. | កញ្ញា | ទៀប ផារិន | ជាមន្ត្រីយេនឌ័រ |
| ៣. | កញ្ញា | ហោ បូផ្សា | ជាមន្ត្រីបរិស្ថាន |



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

**ប្រការ ២.-** សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣.-** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ គ្រប់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តពាក់ព័ន្ធ និងសាមីខ្លួនដូចមានក្នុងប្រការ ១ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**<u>កន្លែងទទួល</u>**

*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
*-មន្ទីរពាក់ព័ន្ធ*
*"ដើម្បីជូនជ្រាប"*
*-ដូចប្រការ៣*
*"ដើម្បីអនុវត្ត"*
*-ឯកសារ - កាលប្បវត្តិ*

ជា សុផារ៉ា